ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០៦២......អ.ស.ហ.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០១៣ អសហ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- បានឃើញប្រកាសលេខ ៣១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Phone: (+855) 23 999 700

# សម្រេច

**ប្រការ ១ ..**

ត្រូវបានតែងតាំងសមាសភាព គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា **(គ.ក.គ.ក.)** ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុក និយ័តករគណនេយ្យនិងសវនកម្ម | ប្រធាន |
| ២- | ឯកឧត្តម **ម៉ូ ចារិន** | អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម | អនុប្រធានប្រចាំការ |
| ៣- | លោក **ឃុន ជាវិទ្ធ** | ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា | សមាជិក |
| ៤- | លោក **សេង តុលា** | អគ្គនាយករងនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ៥- | លោក **ខេន ផាត** | អគ្គនាយករងនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ៦- | លោកស្រី **នាន បូនី** | អគ្គនាយករងនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ៧- | លោក **លី ប៊ុនសោម** | តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨- | លោកស្រី **ជា គីម** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- | ឯកឧត្តម **ឆាង សាក់** | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- | លោក **សោម ផៃ** | តំណាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ១១- | លោកស្រី **ថៃ សុខផល្លីន** | តំណាងនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១២- | លោកស្រី **លុយ ម៉ីអ៊ី** | តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១៣- | លោកស្រី **ហេង ច័ន្ទសុភា** | តំណាងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| ១៤- | ឯកឧត្តម **ណី សាកល** | តំណាងនិយ័តករបរធនបាលកិច្ច | សមាជិក |
| ១៥- | លោក **ឡេង សុខឡុង** | តំណាងនិយ័តករសន្តិសុខសង្គម | សមាជិក |
| ១៦- | លោក **អេង រតនា** | តំណាងអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៧- | លោក **ជា សុជាតិ** | តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ១៨- | ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** | តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា | សមាជិក |
| ១៩- | លោក **សោភាន់ ចែត្រា** | តំណាងបុគ្គលឯករាជ្យក្នុងវិស័យគណនេយ្យនិងសវនកម្ម | សមាជិក |
| ២០- | កញ្ញា **ម៉េង សិរីរតនា** | ប្រធានការិយាល័យអភិវឌ្ឍវិជ្ជាជីវៈនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិកនិងជាលេខាធិការ។ |

**ប្រការ ២ ..**

អាណត្តិរបស់សមាជិកនៃ **គ.ក.គ.ក.** មានរយៈពេល ៣ (បី) ឆ្នាំ។ សមាជិករបស់ **គ.ក.គ.ក.** អាចត្រូវបានផ្លាស់ប្ដូរមុនអាណត្តិត្រូវបានបញ្ចប់ឬបន្តសម្រាប់អាណត្តិរយៈពេល ៣ (បី) ឆ្នាំ បន្តបន្ទាប់ទៀត ដែលត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមសំណើរបស់ប្រធាន **គ.ក.គ.ក.**។

**ប្រការ ៣ ..**

**គ.ក.គ.ក.** ត្រូវអនុវត្តតួនាទី និងភារកិច្ចដូចមានកំណត់នៅក្នុងប្រកាសលេខ ០១៣ អសហ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ស្ដីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ៤ ..**

ប្រកាសលេខ ៤៧៧ ស.ហ.វ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាត្រូវទុកជានិរាករណ៍និងត្រូវជំនួសដោយប្រកាសនេះ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ ..**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និងគ្រប់ស្ថាប័នសាធារណៈពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៦រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:-**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ឯកឧត្ដមនិងលោកជំទាវជាអនុប្រធាន និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ